**Alert.seattle.gov/oiltrain** (ការជូនដំណឹង.seattle.រដ្ឋាភិបាល/រថភ្លើងដឹកប្រេង)

**ករណីពិត ៖** ករណីរថភ្លើងដឹកប្រេងរធ្លាក់ផ្លូវ គឺជាប្រភេទឧបទ្ទវហេតុ បង្ករគ្រោះអាសន្ន ដ៏គ្រោះថ្នាក់មួយ ដោយសារហានិភ័យខ្ពស់ ចំពោះករណីផ្ទុះឡើង ដោយមានលេចចេញប្រេង ឬសារធាតុគីមី និងសារធាតុគ្រោះថ្នាក់ផ្សេងៗ ទៀត ទៅក្នុងបរិស្ថាន ។ នៅពេលនោះ សេចក្តីបង្គាប់ជម្លៀសចេញ ឬសេចក្តីបង្គាប់ប្រាប់ឱ្យ នៅនឹងកន្លែងក្នុងទីជម្រក អាចមានចេញផ្សព្វផ្សាយ តាមផ្នែកនានានៃ Seattle ផងដែរ ដើម្បីធានា ឱ្យមានសុវត្ថិភាព ជាសាធារណៈ ។

**អ្វីដែលត្រូវធ្វើ ៖**

- អនុវត្តតាមការណែនាំទាំងអស់ ដែលបានផ្តល់ឱ្យដោយអ្នកឆ្លើយតបនឹងគ្រោះអាសន្ន ។ លោកអ្នកអាចត្រូវបានប្រាប់ ឱ្យចាក់ចេញពីតំបន់ ឬនៅនឹងកន្លែង អាស្រ័យតាមទីតាំងរបស់លោកអ្នក ។ ត្រូវចាកចេញឱ្យបានឆាប់ នៅពេលមានការប្រាប់ឱ្យចាកចេញ ។
- កុំជ្រៀតជ្រែកជាមួយការងារឆ្លើយតបនឹងគ្រោះអាសន្ន ។
- ប្រសិនបើមានការប្រាប់ឱ្យជ្រកនៅនឹងកន្លែង នាំក្រុមគ្រួសារ និងសត្វចិញ្ចឹមរបស់លោកអ្នកឱ្យនៅក្នុងផ្ទះ ។ បិទទ្វារ បង្អួច និងឡដុតកំដៅ ។ ដាក់កន្សែងពោះគោសើម នៅច្រកទ្វារ ចូល និងច្រកផ្សេងៗ ទៀត ដែលអាចឱ្យកំស្ទួលពីខាងក្រៅ ចូលបាន ។ បិទកង្ហារ ម៉ាស៊ីនត្រជាក់ ប្រព័ន្ធកំដៅ និងប្រព័ន្ធផ្សេងទៀត ដែលបូមខ្យល់ពីខាងក្រៅ ។ ត្រៀមលក្ខណៈ នឹងធ្វើការកែច្នៃ ហើយប្រើអ្វីដែលលោកអ្នកមាននៅក្នុងដៃ ដើម្បីបិទរន្ធចន្លោះ ដើម្បីបិទបាំងខ្លួនលោកអ្នក ពីខ្យល់ខាងក្រៅ ។
- ប្រសិនបើមានការប្រាប់ឱ្យជម្លៀសចេញ សូមធ្វើតាមភ្លាម ។ ទៅតាមផ្លូវដែលបានណែនាំប្រាប់ ដូចមានផ្តល់ជូននៅក្នុងសេចក្តីជូនដំណឹងអំពីការជម្លៀសចេញ ។ ផ្លូវមួយចំនួនអាចមានផ្លាកសញ្ញា ដាក់នៅតាមបណ្តោយផ្លូវ និងវិថីធំៗ ។
- ជៀសវាងតំបន់ដែលមានឧបទ្ទវហេតុរថភ្លើងរធ្លាក់ផ្លូវ ឬបុកទង្គិចគ្នា ។
- ស្តាប់វិទ្យុ ដើម្បីទទួលបានបច្ចុប្បន្នភាព ពីព័ត៌មានស្តីពីគ្រោះអាសន្ន ។
- *ប្រសិនបើលោកអ្នកស្គាល់បុគ្គលដែលមិនអាច យល់ មើលឃើញ ឬដឹងឮ អំពីសារនេះបានទេសូមជួយប្រាប់ពួកគេផង ។*

តំណរបណ្ដាញដែលមានប្រយោជន៍ ៖

http://dot111.info/

http://www.fra.dot.gov/Page/P0001